## ១. តើនរណាខ្លះអាចចូលជាសមាជិក ខេមបូចាបាន?

ដើម្បីអាចចូលជាសមាជិកខេមបូចា លោកអ្នកត្រូវតែមានសញ្ជាតិខ្មែរ និង កំពុងបំពេញការងារក្នុងវិស័យសារព័ត៌មានក្នុងទម្រង់ផ្សេងៗដូចជា៖

- ជាបុគ្គលិកផ្នែកនិពន្ធនៅតាមស្ថាប័នសារព័ត៌មាននានា នៅក្នុងតួនាទីជា អ្នកកាយការណ៍ព័ត៌មាន ការីនិពន្ធ និពន្ធនាយក អ្នកថតរូប អ្នកផលិតវីដេអូ អ្នកផលិតកម្មវិធី ឬ អ្នកអានព័ត៌មានជាដើម
- ជាអ្នកសារព័ត៌មានប្រកបការងារដោយខ្លួនឯង (អ្នកសារព័ត៌មាន Freelance) ឬអ្នកបំពេញព័ត៌មាន (Fixer)
- ជាអ្នកសារព័ត៌មានមហាជន ដែលសកម្មក្នុងការសរសេរ និងរាយការណ៍ព័ត៌មាន (Active Citizen Journalists)
- អ្នកបម្រើក្នុងផ្នែកផ្សព្វផ្សាយព័ត៌មាននៅតាមស្ថាប័នសង្គមស៊ីវិល (Media workers)
- អ្នកសរសេរប្លុកក្នុងទម្រង់អត្ថបទ (Bloggers) ឬ ទម្រង់វីដេអូ (Vloggers) ដែលសកម្មក្នុងការរាយការណ៍អំពីបញ្ហាសង្គម។

## ២. របៀបចុះឈ្មោះ និងដាក់ពាក្យសុំចូលជាសមាជិក

បំពេញពាក្យសុំចូលជាសមាជិកនៅការិយាល័យខេមបូចា ឬ ដាក់ពាក្យតាមរយៈគេហទំព័រខេមបូចា https://www.camboja.net/membership

## ៣. ការពិនិត្យនិងផ្ទៀងផ្ទាត់លើពាក្យស្នើសុំចូលជាសមាជិក

- ក្រោយពេលទទួលបានពាក្យសុំចូលជាសមាជិក គណៈកម្មាធិការដែលមានសមាសភាពចំនួន៣រូប ចាត់តាំងដោយគណៈគ្រប់គ្រងនៃខេមបូចា នឹងជួបប្រជុំប្រចាំខែ ( នៅរៀងរាល់ចុងខែ) ដើម្បីពិនិត្យផ្ទៀងផ្ទាត់ រាល់ព័ត៌មានដែលបានបំពេញដោយបេក្ខជននៅក្នុងពាក្យស្នើសុំចូលជាសមាជិក និងសម្រេចលើពាក្យស្នើសុំទាំងនោះ។
- គណៈកម្មាធិការនឹងធ្វើការសម្រេចក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ ក្រោយពេលទទួលបានពាក្យស្នើសុំចូលជាសមាជិក។
- គណៈកម្មាធិការមានសិទ្ធិបដិសេធសំណើសុំចូលជាសមាជិក ប្រសិនបើពិនិត្យឃើញថាបេក្ខជនមិនបានបំពេញតាមលក្ខន្តិកៈរបស់ខេមបូចា។

### អំពីគណៈកម្មាធិការ

គណៈកម្មាធិការ មានតួនាទីសំខាន់នៅក្នុងការពិនិត្យ និងសម្រេចលើពាក្យសុំចូលសមាជិកខេមបូចា សិក្សាអំពីសាវតារបស់បេក្ខជនដែលបានដាក់ពាក្យស្នើសុំនិងសម្រេចលើពាក្យស្នើសុំនោះ។

សមាសភាពសមាជិកគណៈកម្មាធិការទាំង ៣រូបរួមមាន៖
១. មន្ត្រីគ្រប់គ្រងកម្មវិធីស្រាវជ្រាវ និងតស៊ូមតិ
២. មន្ត្រីគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព និង
៣. អ្នកសម្របសម្រួលផ្នែកទំនាក់ទំនង និងកៀរគរធនធាន

## ៤. ការសម្រេចអនុញ្ញាតឱ្យចូលជាសមាជិក

- ក្រោយពេលគណៈកម្មាធិការសម្រេចអនុញ្ញាតឱ្យបេក្ខជនណាម្នាក់ចូលជាសមាជិក ខេមបូចានឹងធ្វើការជូនដំណឹងទៅដល់បេក្ខជនតាមមធ្យោបាយផ្សេងៗក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃ (ថ្ងៃធ្វើការ)។
- ក្រោយពេលទទួលបានការជូនដំណឹងអំពីការទទួលស្គាល់ជាសមាជិក បេក្ខជននឹងត្រូវបង់ប្រាក់សមាជិកភាពនៅក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ។

## ៥. ការបង់ប្រាក់សមាជិកភាព

គ្រប់សមាជិកខេមបូចាទាំងអស់មានកាតព្វកិច្ចត្រូវបង់ប្រាក់សមាជិកភាពឱ្យបានទៀងទាត់ និងទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- បង់ប្រាក់សមាជិកភាពប្រចាំឆ្នាំចំនួន ៩៦ ០០០រៀល ( ស្មើនឹង ២៤ដុល្លារអាមេរិក) ឬ
- បង់ប្រាក់ពីរដងក្នុងមួយឆ្នាំ ( ៦ខែម្តង)ចំនួន ៤៨០០០រៀល ( ស្មើនឹង ១២ដុល្លារអាមេរិក)។

# គោលការណ៍ណែនាំ អំពីការចូលជាសមាជិក ខេមបូចា




## ៦. អត្ថប្រយោជន៍សម្រាប់សមាជិក

សមាជិកទាំងអស់របស់ខេមបូចានឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើនដូចខាងក្រោម៖

- សេវាការពារផ្នែកច្បាប់ជាមេធាវីដោយឥតគិតថ្លៃ នៅពេលមានបណ្តឹងផ្លូវច្បាប់ទាក់ទងនឹងការងារវិជ្ជាជីវៈ
- សេវាប្រឹក្សាយោបល់ផ្នែកច្បាប់ និងសុខភាពផ្លូវចិត្តដោយឥតគិតថ្លៃ
- ឱកាលចូលរួមក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកម្មវិធីផ្សេងៗដែលរៀបចំដោយខេមបូចា និងអង្គការដៃគូរបស់ខេមបូចា
- ឱកាសចូលរួមក្នុងសន្និបាតប្រចាំឆ្នាំរបស់ខេមបូចា
- ឱកាសទទួលបានថវិកាដើម្បីផលិត និងផ្សព្វផ្សាយព័ត៌មាននៅលើគេហទំព័រព័ត៌មានខេមបូចា
- ប័ណ្ណសម្គាល់សមាជិកខេមបូចា (ការធ្វើប័ណ្ណសម្គាល់ខ្លួនជូនដល់សមាជិកថ្មីធ្វើឡើងរៀងរាល់ ៣ខែម្តងៗ)
- ការជួយសម្របសម្រួលដើម្បីទទួលបានប័ណ្ណសម្គាល់អ្នកសារព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន។

## ៧. ការបញ្ចប់សមាជិកភាព

ខេមបូចាអាចបញ្ចប់សមាជិកភាពរបស់សមាជិកក្រោមមូលហេតុណាមួយក្នុងចំណោមមូលហេតុដូចខាងក្រោម៖

- ទទួលបានពាក្យស្នើសុំបញ្ចប់សមាជិកភាពពីសំណាក់សាមីខ្លួន
- មិនបានបង់ប្រាក់សមាជិកភាព (ក្នុងរយៈពេល ៣ខែ)
- ប្តូរការងារថ្មីដែលមិនស្ថិតក្នុងវិស័យព័ត៌មាន និង ខុសពីលក្ខន្តិកៈចែងដោយខេមបូចា
- បានប្រព្រឹត្តកំហុសធ្ងន់ធ្ងរក្នុងការងារសាព័ត៌មាន ឬ ទង្វើណាមួយដែលប៉ះពាល់ខ្លាំងដល់ខេមបូចា

## ៨. ការផ្សព្វផ្សាយពីសមាជិកភាព

ខេមបូចាអាចប្រកាសជាសាធារណៈតាមរយៈគេហទំព័រ និងបណ្តាញសង្គមរបស់ខ្លួនអំពីការទទួលយកបេក្ខជនណាម្នាក់ជាសមាជិករបស់ខេមបូចាលុះត្រាតែទទួលបានការឯកភាពពីសាមីខ្លួន។

> “រាល់ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសមាជិកត្រូវបានរក្សាការណ៍សម្ងាត់ ដរាបណាមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីសាមីខ្លួនក្នុងការបង្ហាញជាសាធារណៈពីសមាជិកភាពរបស់ខ្លួនទេ។”

ខេមបូចា
CambojA

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance Association

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

096 71 608 71 / 085 94 71 90
Email: communications@camboja.net